# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ គាំទ្រច្បាប់ឯកពន្ធភាពប្តីមួយប្រពន្ធមួយ ដែលរដ្ឋសភាខ្មែរ បានអនុម័តកន្លងមកនេះ

web site: www.hoksavann,org

ថ្ងៃទី១១ តុលា ២០០៦

ក្នុងពេលថ្មីៗនេះ រដ្ឋសភាប្រទេសកម្ពុជាបានអនុម័តច្បាប់ឯកពន្ធភាពប្តីមួយប្រពន្ធមួយ ទោះបីសមាជិកសភានៃគណបក្សហ៊្វុនស៊ិនប៉ិចនិងគណបក្សសម-រង្ស៊ី មិនយល់ស្របហើយដើរចេញក៏ដោយ ។ គម្រោងច្បាប់នេះស្នើដោយគណបក្សប្រជាជនកម្ពុជា ។ គួរកត់សំគាល់ថា គ្រប់គំរោងច្បាប់ដែលស្នើដោយគណបក្សប្រជាជនកម្ពុជាតែងតែបានសំរេច បន្ទាប់ពីបានអនុម័តច្បាប់ភាគច្រើនដាច់ខាត៥០+១ មក ។ ច្បាប់នេះទោះបីពុំទាន់បានសំរេចជាស្ថាពរ ដោយត្រូវឆ្លងកាត់ព្រឹទ្ធសភា និងត្រូវឡាយព្រះហត្ថលេខាដោយព្រះមហាក្សត្រក៏ដោយ ក៏គ្មានឧបសគ្គអ្វីឡើយ ព្រោះសមាជិកសភានៃគណបក្សប្រជាជនកម្ពុជា មានចំនួនច្រើនគ្រប់គ្រាន់ ។

យើងជាអ្នកគោរពព្រះធម៌របស់ព្រះពុទ្ធសាសនា សូមគាំទ្រនូវខ្លឹមសារនៃច្បាប់នេះ ទោះបីច្បាប់នេះមានអ្នកយល់ស្របមានអ្នកប្រឆាំង ឬអ្នកផ្តើមបង្កើតច្បាប់នេះមានគោលដៅនយោបាយបែបណាក៏ដោយ ។ បានជាយើងគាំទ្រ ព្រោះច្បាប់នេះស្របតាមព្រះធម៌របស់ព្រះពុទ្ធសាសនា ត្រង់វគ្គមួយដែលព្រះពុទ្ធសំដែងឲ្យស្វាមីនិងភរិយាសង្គ្រោះគ្នាទៅវិញទៅមកដោយស្ថាន៥យ៉ាង គឺឲ្យស្វាមីនិងភរិយាស្មោះត្រង់នឹងគ្នា កុំក្បត់ចិត្តគ្នា គឺកុំឲ្យមានស្រី ឬបុរសផ្សេងទៀត គឺត្រូវស្មោះត្រង់នឹងគ្នាមួយនិងមួយ ដូចគោលគំនិតច្បាប់នេះ ។ ព្រះពុទ្ធបានសំដែងព្រះធម៌នៃច្បាប់នេះរាប់ពាន់ឆ្នាំមកហើយ ប៉ុន្តែអ្នកខ្លះពុំធ្វើតាម ជាពិសេសពុទ្ធសាសនិកជនខ្មែរ ឥឡូវបានច្បាប់រដ្ឋហាមបន្ថែម រហូតដល់ធ្វើទោសទណ្ឌកម្មដល់អ្នករំលោភច្បាប់នេះទៀត យើងសង្ឃឹមថា ព្រះធម៌នៃព្រះពុទ្ធត្រង់ចំណុចនេះនឹងមានប្រសិទ្ធិភាព ។ អ្នកខ្លះយល់ថា ច្បាប់នេះរំលោភលើសិទ្ធិបុគ្គល ប៉ុន្តែយើងយល់ផ្ទុយទៅវិញ គឺច្បាប់នេះជំរុញឲ្យបុគ្គលជាស្វាមីនិងភរិយាគោរពសិទ្ធិគ្នាទៅវិញទៅមកវិញទេ ។ បុគ្គលជាស្វាមីនិងភរិយា បើនៅជាមួយគ្នាមិនបានទេ មានសិទ្ធិលះលែងគ្នា ហើយយកភរិ-

យានិងស្វាមីរៀងខ្លួន ។ បានសេចក្តីថា បើពុំទាន់លះលែងគ្នាទេ បើស្វាមីទៅយកស្រីណាមួយទៀត ឈ្មោះថារំលោភលើសិទ្ធិភរិយារបស់ខ្លួន ។ ក៏ដូចគ្នាដែរ បើភរិយាទៅយកបុរសណាមួយទៀត ក៏ឈ្មោះថារំលោភលើសិទ្ធិស្វាមីរបស់ខ្លួន ។ យើងធ្លាប់បានធ្វើសំណើមិនចំពោះតែប្តីមួយប្រពន្ធមួយទេ គឺបានធ្វើសំណើនាយករដ្ឋមន្ត្រីឲ្យមានតែពីរអាណត្តិ និងសមាជិករដ្ឋមន្ត្រីរដ្ឋការ មុននឹងឡើងទៅកាន់តំណែង ត្រូវប្រកាសទ្រព្យសម្បត្តិរបស់ខ្លួន ។ នៅពេលនេះ យើងសូមធ្វើសំណូមពរ បើច្បាប់ប្តីមួយប្រពន្ធមួយនេះ បានកើតចេញជាស្ថាពរហើយ ត្រូវតែទទួលការគោរពពីគ្រប់ឋានៈមនុស្ស ទាំងប្រជាពលរដ្ឋទាំងអ្នករដ្ឋការ ហើយអ្នកប្រព្រឹត្តខុសក៏ត្រូវតែទទួលទោសដូចគ្នា ។

ព្រះពុទ្ធសំដែងឲ្យមនុស្សមានការសន្តោសក្នុងកាមគុណ មិនប្រព្រឹត្តអំពើអបាយមុខ ដែលជាប្រធាននៃសេចក្តីវិនាស ដូចជាល្បែងស្រីល្បែងស្រា និងល្បែងស៊ីសងជាដើម ។ ប្តីប្រពន្ធត្រូវស្មោះត្រង់នឹងគ្នា មិនក្បត់ចិត្តគ្នា គឺមិនមានស្រីឬបុរសផ្សេងទៀត ទើបសង្គមគ្រួសារមានសុខដមរមនា មិនទាស់ទែងខ្វែងគំនិតគ្នា ។ តាមការសង្កេត ក្នុងសង្គមខ្មែរ ការកើតរោគអេដ៍ពាសពេញប្រទេស ដោយការមិនសន្តោសក្នុងកាមគុណ ជាពិសេសមិនត្រេកអរនឹងប្រពន្ធខ្លួន តែទៅរកស្ត្រីដទៃទៀត រហូតដល់មានរោគអេដ៍នេះមកចម្លងឲ្យប្រពន្ធខ្លួនទៀត ។ យើងក៏បានធ្វើសេចក្តីអំពាវនាវជាញឹកញាប់ ឲ្យបិទស្រីបន ដែលជាប្រភពនាំឲ្យកើតរោគអេដ៍ ប៉ុន្តែអាជ្ញាធរខ្មែរធ្វើមិនដឹងមិនឮ ព្រោះគេនៅពីក្រោយមុខរបរនេះ ។ មិនត្រឹមតែមិនបិទទេ ថែមទាំងប្រាប់មធ្យោបាយឲ្យប្រព្រឹត្តថែមទៀត គឺប្រាប់ជាប្រយោលថា ត្រូវពាក់ស្រោមអនាម័យ ។ អំពើហឹង្សាមួយភាគធំ កើតមកពីការដណ្តើមស្នេហាគ្នា ដូចជាការលួចសម្លាប់គ្នា ការចាក់ទឹកអាស៊ីដដាក់គ្នាជាដើម ។ ការប្រច័ណ្ឌគ្នា ការទាស់ទែងគ្នាក្នុងសង្គមគ្រួសារ មកអំពីប្តីប្រពន្ធមានសេចក្តីស្នេហាពុំស្មោះត្រង់នឹងគ្នា ។ អ្នកធំអ្នកមានអំណាច អ្នកមានប្រាក់ច្រើន តែងយកអំណាចយកប្រាក់ ទៅបោកបញ្ឆោត របៀបទិញដូរយកស្រី មានវ័យក្មេងមកប្រព្រឹត្តកាមគុណ ។ អំពើអមនុស្សធម៌របស់អ្នកទាំងនោះ ពុំមានការអៀនខ្មាស់អ្វីឡើយ សូម្បីខ្លួនគេមានវ័យចាស់ជរាហើយក៏ដោយ ក៏គេតែងប្រព្រឹត្តដើម្បីសេចក្តីសប្បាយលើគំនរទុក្ខអ្នកដទៃ ជាកត្តាបង្ហាញឲ្យឃើញថា សីលធម៌សង្គមខ្មែរបានត្រូវធ្លាក់ចុះយ៉ាងខ្លាំង ។ គេតែងនិយាយថា ស្ត្រីមានរូបល្អដូចស្រីរបាំ ស្រីរាំការាអូខេ ស្រីតួឯកកុនល្ខោន ឬស្រីដែលគេជ្រើសរើសរូបសម្បត្តិជាប់លេខជាដើម គេចមិនផុតពីកណ្តាប់ដៃនៃអ្នកមានអំណាចបុណ្យស័ក្តិនិងទ្រព្យសម្បត្តិ លួងលោមឬគំរាមកំហែងយកមកធ្វើជាស្រីកំណាន់ចិត្ត ឬប្រពន្ធចុងបានឡើយ ។

ដូចពោលមកនេះបញ្ជាក់ថា អ្នកដែលជួញដូរមនុស្ស គឺកើតឡើងពីអ្នកមានអំណាចមួយភាគ ។ ដូច្នេះបើកំចាត់ការជួញដូរមនុស្ស ត្រូវកំចាត់ពីថ្នាក់ជាមុន ដូចស្ត្រី

ដែលបំរើការនៅសណ្ឋាគារឆៃហ្គីរនៅភ្នំពេញជិត១០០នាក់ ដែលមានការបំរើផ្លូវភេទផង ហើយដែលមានការពាក់ព័ន្ធនឹងអាជ្ញាធរខ្មែរ ត្រូវរដ្ឋាភិបាលសហរដ្ឋអាមេរិកគំរាមខ្លាំង ទើបអាជ្ញាធរខ្មែរធ្វើជាចាប់ថៅកែនៃសណ្ឋាគារនេះដាក់គុក ដើម្បីបំបិទដាន ។ អ្នករដ្ឋការដែលមានស្រីច្រើន នាំឲ្យប្រព្រឹត្តអំពើពុករលួយ ដើម្បីឲ្យទៅបំពេញកង្វះខាតរបស់ខ្លួនក្នុងកាមគុណ ។ អំពើពុករលួយមួយភាគរបស់មន្ត្រីអ្នករដ្ឋការកើតឡើងពីភរិយាឬស្រីកំណាន់ចិត្ត និយាយបញ្ចុះបញ្ចូលប្ដីឲ្យប្រព្រឹត្ត ។ មធ្យោបាយមួយដែលអ្នកសូកយកមកប្រើ គឺបើគេចង់បានតំណែងអ្វីមួយ ឬឲ្យជួយអ្វីមួយ គេទៅនិយាយសូកភរិយារបស់មន្ត្រី ដែលទទួលខុសត្រូវក្នុងការចាត់តាំងតំណែងអ្វីមួយ ដូចជាអំណាចរបស់នាយករដ្ឋមន្ត្រីជាដើម ដោយចង់បានប្រាក់ក៏សន្យាទៅនិយាយជាមួយស្វាមីឲ្យជួយ ដើម្បីខ្លួនបានសំណូក ។ គេតែងនិយាយថា ភរិយាឬស្រីកំណាន់ចិត្ត ជាទីប្រឹក្សារបស់ស្វាមី ព្រោះនៅណែបនិត្យជាមួយគ្នារាល់ថ្ងៃ ជាងទីប្រឹក្សាដែលតែងតាំងត្រឹមត្រូវតាមច្បាប់ទៅទៀត ។ ដូច្នេះហើយបានជាប្រទេសដែលកាន់របបប្រជាធិបតេយ្យខ្ពស់ មុននឹងតែងតាំងជនណាម្នាក់ ឲ្យធ្វើជារដ្ឋមន្ត្រីមាននាយករដ្ឋមន្ត្រីជាដើម គេតែងពិនិត្យមើលបុគ្គលិកលក្ខណៈ និងអាកប្បកិរិយាភរិយារបស់ជននោះជាមុនសិន ព្រោះគេយល់ថា បើភរិយាមានគំនិតមិនល្អ តែងឲ្យយោបល់ប្ដីប្រព្រឹត្តអាក្រក់ មានការប្រព្រឹត្តអំពើពុករលួយជាដើម នេះនិយាយពីជនដែលមានភរិយាតែមួយ បើមានស្រីកំណាន់ចិត្តថែមទៀត រឹតតែមានបញ្ហាជាងនេះថែមទៀតក្នុងឋានៈខ្លួនជានីតិបុគ្គលទទួលខុសត្រូវក្នុងបញ្ហាជាតិផ្នែកណាមួយ។

ជាថ្មីទៀត យើងនៅតែគាំទ្រឯកពន្ធភាពប្ដីមួយប្រពន្ធមួយ ដែលសភាខ្មែរបានអនុម័តកន្លងមកនេះ ទោះបីច្បាប់នេះមានគោលបំណងផ្សេងបែបណាក៏ដោយ ព្រោះជាច្បាប់មានខ្លឹមសារ ស្របតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ត្រង់វគ្គមួយថា ប្ដីនិងប្រពន្ធត្រូវស្មោះត្រង់និងគ្នា កុំក្បត់ចិត្តគ្នាទៅយកស្រីឬបុរសផ្សេងទៀត ហើយស្របតាមវប្បធម៌ថ្លៃថ្នូររបស់ខ្មែរ ដែលមានតាំងពីបូរាណមក ត្រង់ពាក្យថា ប្ដីនិងប្រពន្ធត្រូវរស់នៅជាមួយគ្នាអស់មួយជីវិត កុំទាស់ទែងខ្វែងគំនិតគ្នា កុំឲ្យមានមួយជាពីរ នេះជាពាក្យរបស់អាចារ្យឲ្យពរនៅពេលរៀបការ ។ ពាក្យនេះក្លាយជាការពិត ព្រោះគ្រួសារខ្មែរ ស្វាមីភរិយាតែងរស់នៅជាមួយគ្នារហូតចាស់ព្រឹទ្ធចាស់ព្រេងកម្រមានបែកចិត្តពីគ្នាណាស់ ។៚

❑ ❑

❑